# កិច្ចសំភាសន៍លោកពូឈឹម ផារឹទ្ធ

កៈ អ្នកធ្វើការសំភាសន៍ កុសល្យ វឌ្ឍនៈនិមល ខៈ អ្នកត្រូវគេសំភាសន៍ ឈឹម ផារឹទ្ធ

កៈ (សំលេងឡាន) ចាសជំបូងសុំជំរាបសួរលោកពូ!

ខៈ បាទ សួស្តីអូន (សំលេងអ្នកដទៃ)!

កៈ
ចាសថ្ងៃនឹងខ្ញុំមានឳកាសដែលបានមកសំភាសន៍លោកពូផ្ទាល់ហើយការសំភាសន៍នេះផងដែរធ្វើឡើងនៅថ្ងៃទី៦ ខែ៦ឆ្នាំ២០២៨ ដែលអឺ.....ខ្ញុំគឺជាអ្នកស្ម័គ្រចិត្តនៅគំរោងរបស់សាលា BYU ហាវ៉ៃខាងសហរដ្ឋអាមេរិកដែលយើងធ្វើការសំភាសន៍ប្រជាជកម្ពុជាដែលគាត់មានវ័យចាប់ពីអាយុ៣៥ឡើងដែលបានឆ្លងកាត់សម័យពលពតហើយនឹងជីវប្រវត្តិរបស់គាត់តាំងពីមុនរហូតមកដល់សម័យឥលូវ
ហើយចឹងតើលោកពូអនុញ្ញាតអោយខ្ញុំយកសំលេងរបស់លោកពូទៅដាក់ក្នុងវេបសាយខាងសាលាដែរឬទេ(សំលេងម៉ូតូ)?

ខៈ អត់អីទេអូនអាចយកទៅធ្វើបានណាស់!

កៈ ចាសអរគុណច្រើនលោកពូ ចឹងជាជំបូងលោកពូៗមានឈ្មោះអីដែរ?

ខៈ អឺ....ឈ្មោះ ឈឹម ផារឹទ្ធ (សំលេងរំខានពីខាងក្រៅ)!

កៈ លោកពូឈឹន ផារឹទ្ធ ចាសហើយលោកពូឈ្មោះនឹងត្រូវនឹងអត្តសញ្ញាណប័ណដែរឬទេ?

ខៈ នឹងហើយបាទត្រូវតាមអត្តសញ្ញាណប័ណផ្ទាល់ខ្លួនម៉ង!

កៈ ឈ្មោះពេញគឺចឹងម៉ង.....

ខៈ ឈឹម ផារឹទ្ធនឹងម៉ង!

កៈ ចាសលោកពូ!

ខ៖ បាទ

ក៖ ចាសលោកពូ ហើយសព្វថ្ងៃលោកពូមានអាយុប៉ុន្មានឆ្នាំហើយ(សំលេងរំខាន)?

ខ៖ ឆ្នាំនឹង៤០ហើយ!

ក៖ ៤០ ឆ្នាំហើយ!

ខ៖ បាទ!

ក៖ ចាសហើយលោកពូថ្ងៃខែឆ្នាំកំណើតខ្លួនឯងលោកពូចាំដែរទេ?

ខ៖ ថ្ងៃ៩ ខែ៩ ឆ្នាំ៧៩!

គ៖ តាប៉ែ ពោតកំបោ សួយ (សំលេងអ្នកលក់នំ)!

ក៖ ចុះឆ្នាំត្រូវជាខ្មែរយើងចន្ទគតិសុរិយគតិលោកពូចាំដែរទេ?

ខ៖ ថ្ងៃ៩ កញ្ញា ត្រូវនឹងឆ្នាំមមែអឺ....៩!

គ៖ ត្រប៉ែ ពោតកំបោ សួយ(សំលេងអ្នកលក់នំ)!

ខ៖  កញ្ញានឹងត្រូវជាថ្ងៃ១៣ កើត ខែភទ្របទទៀត!

ក៖ ចាសលោកពូ(សំលេងម៉ូតូ)ហើយចុះសព្វថ្ងៃនេះលោកពូមានទីលំនៅៗឯណាដែរ?

ខ៖ នៅភ្នំពេញនឹងអូន
នៅម្តុំស្ទឹងមានជ័យយើងនឹងភូមិឫស្សីនៅភូមិឫស្សីយើងនឹង(សំលេងមនុស្សស្រី)!

ក៖ ចាស ចុះលោកពូមានស្រុកកំណើតនៅឯណាដែរ?

ខ៖ កើតនៅនឹងភ្នំពេញនឹងម៉ង!

ក៖ នៅភ្នំពេញតែម្តង ចាសហើយលោកពូសព្វថ្ងៃមានគ្រួសារហើយ?

ខ៖ មានហើយ!

កៈ ចាសភរិយារបស់លោកពូឈ្មោះអីដែរ?

ខៈ ប្រពន្ធខ្ញុំឈ្មោះ ជា សុខុម អាយុ៥០ ឆ្នាំដូចគ្នា!

កៈ ចាសហើយអឺ.....លោកពូមានកូនប៉ុន្មាននាក់ដែរសព្វថ្ងៃ?

ខៈ ពីរនាក់ប្រុសមួយស្រីមួយ!

កៈ ពួកគាត់រៀបការឬនៅលោកពូ?

ខៈ នៅទេ....នៅកំពុងរៀននៅឡើយ!

កៈ រៀនថ្នាក់ទីប៉ុន្មានហើយលោកពូ?

ខៈ បងគេរៀនថ្នាក់ទី៣ ហើយប្អូនទើបតែចូលរៀជនសាលាឯកជនឆ្នាំទីមួយ (ថ្នាក់ទីមួយ)!

កៈ អូ....ចាស!

ខៈ នឹងហើយបាទ!

កៈ ចាសហើយអឺ....លោកពូសព្វថ្ងៃលោកពូរស់នៅក្នុងភ្នំពេញលោកពូមានមុខរបរធ្វើអីដែរ?

ខៈ ជាមេការសំណង់!

កៈ អូ! ដូចជាម៉ៅការអី......

ខៈ នឹងហើយ!

កៈ សាងសង់អាគារអី.....

ខៈ
នឹងហើយម៉ៅការតាមផ្ទះតាមអាគារឬក៏អាចតាមក្រុមហ៊ុនអីខ្លះៗដែរទៅតាមលទ្ធភាពដែលអាចធ្វើបាន!

កៈ ចាស
ហើយចុះលោកពូការងារនឹងធ្វើតែនៅភ្នំពេញឬក៏យើងជួនកាលយើងទៅតាមខេត្តដែរ?

ខ៖ ធ្វើទៅតាមខេត្តដែរតើអូន អត់ទៀងដែរមានការងារនៅខេត្តយើងទៅខេត្ត!

ក៖ ចាស!

ខ៖ មានការងារនៅភ្នំពេញយើងធ្វើនៅភ្នំពេញទៅ ប៉ុន្តែភាគច្រើនយើងធ្វើនៅភ្នំពេញច្រើនជាងនៅភ្នំពេញវាក្បែរផ្ទះផងយើងងាយស្រួលធ្វើការ!

ក៖ ចាស ហើយលោកពូសព្វថ្ងៃលោកពូតាមរយៈការងារនឹងលោកពូធ្វើបានរយៈពេលប៉ុន្មានហើយបទពិសោធន៍នៃការងារនឹងណាស់លោកពូ?

ខ៖ យូរដែរប្រហែលជាចូលប្រាំបីដណ្តប់ឆ្នាំហើយមើលទៅ(ប្រហែលជាដប់ប្រាំបីឆ្នាំហើយ) (សំលេងស៊ីផ្លេម៉ូតូ) ព្រោះអានឹងមុខរបរតដូនតាមក!

ក៖ អូ! ចឹងមានន័យថាមុខរបរនឹងលោកពូចេះតគ្នាមិនមែនបានចេះពីសាលាទេ?

ខ៖ អឺ....(សំលេងម៉ូតូឡាន)ទីមួយយើងចេះមូលដ្ឋានគ្រឹះពីឪពុកពីជីតាណាស់!

ក៖ ចាស!

ខ៖ ហើយយើងបានដកបទពិសោធន៍ផ្ទាល់នឹងបានរៀនសូត្រខ្លះជាមួយនឹងក្រុមហ៊ុនមួយចំនួនធំៗដែរដែលយើងធ្លាប់ធ្វើចឹងណាស់!

ក៖ ចាស!

ខ៖ ព្រោះពូធ្លាប់ទៅធ្វើការច្រើនកន្លែង!

ក៖ ចាស!

ខ៖ ចឹងយើងទៅធ្វើការនៅកន្លែងណាយើងមានបទពិសោធន៍នៅកន្លែងនឹងយើងមានបទពិសោធន៍ច្រើនយកមកបញ្ចូលគ្នាណាស់!

ក៖ ចាស (ស៊ីផ្លេឡាន)!

ខ៖
យើងដកបទពិសោធន៍ពីគេអានេះនិយាយអោយស្រួលស្តាប់យើងដើរលួចគំរិះពីគេយើងលួចគំរិះពីគេយើងយកមកប្រើការបំបែកជាគំនិតខ្លួនឯងផ្ទាល់សំរាប់ប្រើទៅក្នុងការងាររបស់យើងចឹងទៅ!

ក៖ ចាស ហើយលោកពូអឺ.....លោកពូធ្លាប់បានសិក្សានៅសាលាណាដែរលោកពូ?

ខ៖ អឺ.....និយាយពីការបឋមមកម៉ងឬក៏ម៉េច?

ក៖ ចាសចាប់តាំងពីលោកពូសិក្សាពីបឋមរហូត

ខ៖ (ក្រហែម)!

ក៖ មកដល់ថ្នាក់.....

ខ៖ អូ....

ក៖ ថ្នាក់អឺ...បានដល់កំរិតណាចឹងណាស់លោកពូ?

ខ៖ អូ!
ពីបឋមនិយាយទៅធ្លាប់ទៅរៀននៅសាលាបឋមសិក្សាទួលគោកយើងនៅរង្វង់អឺ....នៅរង្វង់មូលទួលគោកណាស់ ហើយចេញមកពីរង្វង់មូលទួលគោកបាន(សំលេងឡាន)
ចេញពីទួលគោកមកបានទៅខាងសាលាឥន្ទ្រទេវីនឹងថ្នាក់វិទ្យាល័យរហូតដល់ឆ្នាំ៩៧
(១៩៩៧)
ពូចប់អឺ....ពីខាងវិទ្យាល័យនឹងពូចូលរៀន(សំលេងមនុស្សប្រុសនិយាយគ្នា)នៅសាលាសិល្បះបីឆ្នាំ!

ក៖ ចាស!

ខ៖
នៅភូមិន្ទវិចិត្រសិល្បះនឹង(សំលេងរំខាន)ភូមិន្ទសិល្បះបីឆ្នាំនឹងបើគិតពីការរៀននៅនឹងបីឆ្នាំហើយនឹងៗការរៀនពេលមួយរយះដែលចូលធ្វើការអោយខាងអង្គការនឹងប្រហែលជាដប់ឆ្នាំ

ហើយយើងមានបទពិសោធន៍ខ្លះៗទៀតពាក់ព័ន្ធនឹងផ្នែកទីផ្សារ ផ្នែករដ្ឋបាល ផ្នែកគ្រប់គ្រងសំរបសំរួល!

គ៖ ម៉េចបានឆ្នាំងដាំបាយនេះអត់ពុះចឹង (សំលេងអ្នកដទៃ)?

ក៖ ចាស ចុះលោកពូមានគំរោងចង់រៀនបន្តដែរឬទេ?

ខ៖វា...យើងចេះតែចង់រៀនហើយប៉ុន្តែការរស់នៅត្រូវការបទពិសោធន៍និងមេរៀនបន្ថែមសំរាប់ជីវិតហើយប៉ុន្តែឥលូវនឹងយើងវាអត់មានពេលវេលាហើយវ័យយើងនឹងក៏វាពិបាកនឹងទទួលយកដែរ!

ក៖ ចាស!

ខ៖ ប៉ុន្តែគ្រាន់តែថាវាមិនមែនថាឈប់ទាំងស្រុងទេយើងរៀនដែររៀនតាមរយះសង្គមតាមរយះអីផ្សេងៗណាស់យើងមិនបានរៀននៅសាលាតែយើងរៀនតាមរយះរបបគំហើញនៃសង្គម....

ក៖ ចាស!

ខ៖ ពីមួយជំនាន់ទៅមួយជំនាន់ចឹងអានឹងយើងអាចយកមកធ្វើជាបទពិសោធន៍នឹងធ្វើជាមេរៀនបាន(សំលេងរញ៉េរញ៉ៃ)!

ក៖ ចាស ចឹងអឺ....លោកពូមានបំណងចង់បន្តដែរប៉ុន្តែអឺ.....ដោយសារតែល័កខណ្ឌមួយចំនួនបានជាតំរូវអោយលោកពូតំរូវអោយលោកពូអត់អាចបន្តបាន.....

ខ៖ យើងគ្មានលទ្ធភាពសំរាប់រៀនយើងត្រូវការប្រើសេដ្ឋកិច្ចហិរញ្ញវត្ថុយើងក៏វាទៅតាមនឹងដែរហើយទីពីរវ័យរបស់យើងក៏វាទទួលអាការសិក្សានឹងក៏វាមិនបានជ្រៀលជ្រៅដូចពីកាលយើងនៅក្មេងដែរ
ហើយទីបីទៀតពេលវាលាការងារយើងអត់អាចដកឃ្លាទៅបានណាស់!

ក៖ ចាស!

ខ៖ សឹងតែថាដើរចោលមិនបានផងនឹង!

ក៖ (សើច) នឹងហើយ! ចាសចឹងលោកពូចេះប៉ុន្មានភាសាដែរលោកពូ?

ខ៖ និយាយស្ទាត់ខ្មែរហើយបើជាមធ្យមប្រើការបានអង់គ្លេសហើយបើធន់មធ្យមថៃ(ភាសាថៃ) អាចប្រើបានខ្លះអាចអានអក្សរបានខ្លះ!

ក៖ ចាស ចឹងភាសាពីរដូចជាភាសាអង់គ្លេសហើយនិងភាសាថៃតើលោកពូចេះត្រឹមកំរិតណាដែរ?

ខ៖ អឺម! ពិបាកស្មានពីកំរិតណាស់បើសិនជាអង់គ្លេស(សំលេងផ្សារដែក)កាលនឹងយើងធ្លាប់ធ្វើការអង្គការខ្ញុំធ្លាប់ធ្វើការអង្គការព្រោះពូនៅធ្វើការម៉ាដណ្តប់ឆ្នាំ(១១ឆ្នាំ) ចឹងអាការដកពិសោធន៍ភាសានិយាយហើយនឹងរៀននឹងវា....នៅជំនាន់នឹងសៀវភៅយើងនឹង Elementary, Book1, 2, 3, 4, 5 អីនឹងណាស់!

ក៖ ចាស!

ខ៖ យើងបានចប់សៀវភៅទីបួនដែរ(សំលេងផ្សារដែកនិងសំលេងម៉ូតូ) Book four and Elementary ដល់ Thirds ដែរណាស់!

ក៖ ចាស!

ខ៖ បានត្រឹមសៀវភៅទីបីកាលនឹង!

ក៖ ចឹងលោកពូអាចចេះនិយាយសរសេរនឹងអាចសន្ទនាអីបាន?

ខ៖ បានៗខ្លះ....

ក៖ ស្តាប់អីបាន?

ខ៖ បានជាមធ្យមប៉ុន្តែថាកន្លែង(សំលេងផ្សារដែក)ខ្លះពាក្យជ្រៅៗក៏យើងលូកមិនដល់ដែរ(បើគេប្រើពាក្យពិបាកៗគាត់មិនចេះទេ) ប៉ុន្តែអាងថាមាន Dictionary

នៅលើទូរស័ព្ទយោងដែរលួចរៀនតាមទូរស័ព្ទខ្លះទៀតណាស់អានឹងណាស់វាមានកម្មវិធីដែលយើង Download តាមទូរស័ព្ទមកសំរាប់បកប្រែឧទាហរណ៍ថាហ៎ពាក្យណាយើងអត់ចេះយើងថតក្រឹបយកមកយើងបញ្ចូលនៅក្នុងទូរស័ព្ទយើងទៅវាលោតជាភាសាមកបកប្រែអោយយើងហើយយើងចំណាំអានឹងមួយទុកទៅចឹងនឹងដែលពូខ្លាំងបានអានឹងដែរក៏អាចជួយយើងបានមួយកំរិតដែរ!

ក៖ ចាស ហើយចុះភាសាថៃក៏ចឹងដែរន៏លោកពូ?

ខ៖ ថៃចឹងដូចគ្នា!

ក៖ តើភាសាថៃនឹងភាសាអង់គ្លេសតើមួយណាលោកពូខ្លាំងជាង?

ខ៖ អង់គ្លេសៗ!

ក៖ អង់គ្លេសពូកែជាង?

ខ៖ អង់គ្លេសខ្លាំងជាង រាងច្បាស់ជាងបាទ!

ក៖ ចាស ហើយចុះលោកពូបានអឺ...សិក្សាពីសាលាណាដែរឬទេឬក៏រៀនខ្លួនឯងភាសាទាំងពីរនឹង?

ខ៖ អឺ.....កាលនឹងរៀនសាលាឯកជន!

ក៖ ឈ្មោះអីដែរលោកពូ?

ខ៖ អឺ....សាលាឯកជនតែមិនមែនសាលាបើកទូទៅដូចរាល់ថ្ងៃនឹងទេណាស់!

ក៖ សាលាបង្រៀនក្រៅម៉ោង?

ខ៖ កាលនឹងគ្រូ....នឹងហើយគ្រូបង្រៀនក្រៅម៉ោងយើងឆ្លៀតពេលពីម៉ោងដែលយើងរៀនធម្មតាយើងទៅរៀនក្រៅម៉ោងមួយម៉ោងពីរម៉ោងៗក្រៅអីចឹងណាស់ នឹងហើយ!

ក៖ ចាស!

ខ៖ អេ! ដូចជាធ្លាប់រៀននៅជ័យថាវីដែរនៅស៊ីសុវត្ថិនឹងរៀនភាសាក្រៅម៉ោងនឹងណាស់!

ក៖ ចាសៗ!

ខ៖
នឹងហើយនឹងទៅសាលាគ្រូជ័យថាវីនឹងគ្រូស៊ីសុវត្ថិគ្រូសុវណ្ណារីជំនាន់នឹងល្បីណាស់ពីរសាលានឹងល្បីម៉ង!

ក៖ (សើច) ចាសលោកពូហើយអឺ....លោកពូសព្វថ្ងៃនឹងដោយសារតែលោកពូមានបទពិសោធន៍ការងារច្រើនចឹងតើលោកពូមានបានធ្វើការងារកន្លងមកប៉ុន្មានការងារហើយដែលលោកពូចងចាំណាស់?

ខ៖
ការងារវាមានច្រើនដែរហើយមានមួយផ្នែកទៀតដែលអត់បាននិយាយអានឹងផ្នែកសិល្បះកាលយើងនៅរៀនធ្វើការអង្គការនឹងទីមួយវាមានច្រើនដែលគេផ្តោតនៅក្នុងអង្គការនឹងវាមានចែកចេញជាបី វាមានការងារជួយជនក្រីក្រ ចាសជរា កុមារកំព្រារអីនឹងអានឹងមួយ (សំលេងម៉ូតូ) ការងារទីពីរទៀតទីផ្សារ
អឺ....ការងារជាទីផ្សារនឹងធ្វើការរយះពេលបានប្រហែលជាបីឆ្នាំដែរធ្វើការជាមួយ PSR បីទៅបួនឆ្នាំដែរហើយនឹងអឺ...ការងារផ្សព្វផ្សាយចល័តវារបៀបដូចសិល្បះណាស់អឺ....ជំនាន់នឹង (សំលេងផ្សារដែក) ដោយប្រព័ន្ធផ្សព្វផ្សាយដូចជាទូរទស្សន៍ វិទ្យុ(វិទ្យុ) ឬក៏ Facebook អីដូចយើងសព្វថ្ងៃនេះទេអត់មានទូលំទូលាយចឹងទេ(សំលេងផ្សារដែក)
ចឹងកន្លែងតំបន់ចុងកាត់មាត់ញកដាច់ស្រយាលដែលអត់មានប្រព័ន្ធផ្សព្វផ្សាយចូលទៅដល់គឺទាមទារអោយមានក្រុមសិល្បះចល័តសំរាប់ចុះអប់រំពូកគាត់(សំលេងផ្សារដែក)
ពេលថ្ងៃយើងធ្វើការជាមួយក្រុមគោលដៅប្រមូលអ្នកភូមិមកបង្រៀនគាត់ពន្យល់គាត់បង្ហាញគាត់ពីអឺ....គោលដៅការងាររបស់យើងដែលយើងត្រូវធ្វើជាមួយគាត់ដូចជាទាក់ទងទៅនឹងការចំណាកស្រុក
នឹងការជួយទៅលើជនចាសជរាកុមារកំព្រាកុំអោយមានការរើសអើងដូចអ្នកផ្ទុកមេរោគអេដស៍អ្នកជំងឺអេដស៍អីចឹងណាស់អានឹងវាជាគោលដៅដែលយើងធ្វើទាំងបីនឹងនៅក្នុងស្រុកមួយៗនឹងពូធ្វើអឺ....បីខេត្តនៅកំពត
នៅអឺ...(សំលេងផ្សារដែកលឺខ្លាំង)ឧត្តរមានជ័យហើយនឹងអឺ....ប៉ៃលិនកាលនឹងណាស់បីសាខានឹងធ្វើប្រហែលជាជាងដប់ឆ្នាំដែរចឹងយើងសរុបទៅការងារទាំងបីនឹងគឺដើរទន្ទឹមគ្នាម៉ងវាដើរ

ទៅជាមួយគ្នាដើម្បីយើងផ្សព្វផ្សាយបីផ្នែកនឹងអោយចូលគ្នាព្រោះកន្លែងខ្លះអត់មានកន្លែងប្រព័ន្ធផ្សព្វផ្សាយទេទៅដល់អ្នកភូមិគាត់អត់យល់ដឹងទៅលើអាចំនុចទាំងអស់នឹងទេចឹងអាការចំណាកស្រុកអត់អឺ(សំលេងផ្សារដែក)....គោលដៅមួយទៀតអានឹងក៏វាបញ្ហាគ្រោះថ្នាក់សំរាប់ប្រជាជនយើងដែរអានឹងណាស់ហើយនៅជំនាន់នឹងមានមូលិធិ(សំលេងម៉ូតូ)គេសំរាប់ជួយប្រជាជនយើងដែរតែឥលូវអស់ហើយមូលិធិនឹងវាដាច់ហើយ!

ក៖ ចាស!

ខ៖ វាដាច់ហើយ!

ក៖
ហើយអឺ...ចំពោះក្រុមគ្រួសាររបស់លោកពូវិញទាក់ទងជាមួយនឹងឪពុកម្តាយរបស់លោកពូពួកគាត់មានឈ្មោះអ្វីដែរ?

ខ៖ (ក្រហែម) ឪពុកឈ្មោះ ឈឹម ឈិន ហើយម្តាយឈ្មោះឡេង សុណេន!

ក៖ ចាស ពួកគាត់មានទីលំនៅៗភ្នំពេញតើហី......

ខ៖ នៅភ្នំពេញទាំងអស់នឹង!

ក៖ ចឹងសព្វថ្ងៃតើគាត់មានទីលំនៅៗជាមួយលោកពូឬក៏បែកគ្នា?

ខ៖ អត់ទេៗ បងអឺ....ពូបែកផ្ទះហើយ!

ក៖ បែកផ្ទះជាមួយឪពុកម្តាយ?

ខ៖ នឹងហើយយើងមានគ្រួសារទៅយើងមានផ្ទះផ្សេងចឹងណាស់!

ក៖ នឹងហើយ អឺ...លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ទាំងអស់ប្រាំអ្នក!

ក៖ គាត់ឈ្មោះអីខ្លះដែរលោកពូ?

ខ៖ អឺម....បងធំនោះ ឈឹម សុធា ហើយបងទីពីរស្រីឈ្មោះ ឈឹម ធារី បន្ទាប់មកពូឈឹម ធារិទ្ធនឹង មានប្អូនម្នាក់អ៎ពីរនាក់ទៀតម្នាក់ឈឹម ពិសិទ្ធ ម្នាក់ទៀត ឈឹម ពិសាល ប្អូនពៅ តែសុទ្ធតែមានគ្រួសារអស់ហើយ!

ក៖ ចាស ពួកគាត់ទាំងគ្នាស្រីប៉ុន្មានប្រុសប៉ុន្មានដែរបងប្អូនលោកពូ.....

ខ៖ ស្រីតែម្នាក់ទេ ប្រុសបួននាក់!

ក៖ អូ! ហើយលោកពូកូនទីប៉ុន្មានដែរក្នុងគ្រួសារ?

ខ៖ កូនទីបី កូនកណ្តាល!

ក៖ អូ កូនកណ្តាល!

ខ៖ (ក្រហែម)!

ក៖ លោកពូបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំណាដែរលោកពូចាំទេ?

ខ៖ តាមដែរចាំដូចជា ២០១០ ចុងឆ្នាំ ២០០៩ ហើយចុងឆ្នាំ២០០៩ នឹងវា....និយាយទៅបើនិយាយពីរៀបការៗពីរដង(សើច)!

ក៖ អូ ចឹងលោកពូមានភរិយាពីរដង?

ខ៖ អត់ទេតែមួយទេ!

ក៖ តែមួយ...

ខ៖ តែការពីរដង (រៀបការពីរដង)!

ក៖ ហេតុអីទៅលោកពូ?

ខ៖
ពីព្រោះកាលដែលយើងភ្ជាប់ពាក្យនឹងយើងធ្វើមួយសារហើយអស់ជាងដប់តុមួយសារហើយដល់ពេលមកភ្នំពេញៗត្រឡប់មកភ្នំពេញនេះមកការមួយសារទៀតចឹងវាពីរដងនិយាយទៅដូចកាត់ចំណាងដៃចឹងណាស់!

កៈ អូ!

ខៈ ប៉ុន្តែយើងធ្វើខាងស្រុកខាងប្រពន្ធផងយើងធ្វើភ្នំពេញយើងផងចឹងបើនិយាយទៅវាដូចតែការពីរដងចឹង(សំលេងស៊ីផ្លេឡាន) នៅចុងឆ្នាំ ២០០៩ ម្តងដើមឆ្នាំ២០១០ម្តងចឹងបានថាដូចតែរៀបការពីរដងនឹង!

កៈ ចាស(សើច)!

ខៈ ចឹងបានថាការពីរដង!ង

កៈ (សើច) ចឹងមានន័យថាអឹ...ល្អមែនទែនហើយអឹ...លោកពូស្រុកកំណើតអ្នកមីងនៅឯណាដែរ?

ខៈ គេអ្នកអឺ...កំពង់ចាម( សំលេងមនុស្សស្រីសើច)!

កៈ អ្នកកំពង់ចាម?

ខៈ នឹងហើយ!

កៈ ចាស ចឹងហើយទៅគាត់នៅទីរួមខេត្ត?

ខៈ នៅទីរួមខេត្តកំពង់ចាមនឹងម៉ង!

កៈ ចាសៗ ហើយអឺ....ខ្ញុំសុំសួរទាក់ទងជាមួយនឹងប្រវត្តិរបស់លោកពូកាលពីសម័យមុននឹងលោកពូមានបងប្អូនស្លាប់នៅក្នុងជំនាន់ពលពតដែរឬទេ?

ខៈ អឺ....បើតាមមានគឺមានអ៊ុំម្នាក់ហើយនឹងឪពុកមាម្នាក់ គាត់ស្លាប់នៅក្នុងជំនាន់អាពត (សំលេងម៉ូតូ) តែមិនប្រាកដថាគាត់ស្លាប់ដោយសារគេសំលាប់ឬគាត់ស្លាប់ដោយសារជំងឺឬក៏អីទេប៉ុន្តែដឹងតែថាគាត់គឺបាត់ខ្លួនតាំងពីនឹងរហូតមកដល់ថ្ងៃនឹងរកមិនទាន់ឃើញនៅឡើយចឹងណាស់ (ក្រហែម និងសំលេងម៉ូតូ) បាត់ខ្លួននឹងហើយធ្លាប់ប្រកាសស្វែងរកតាមកាសែតតាមអីនឹងកម្មវិធីផ្សេងៗដែលគេស្វែងរក

សាច់ញ្ញាតិដែរតែយើងរកអត់ឃើញណាស់អត់មានដំណឹងស្ងាត់ឈឹងទៅចឹងក៏សន្និដ្ឋានថា ៨០% ពួកគាត់អាចស្លាប់ (សំលេងផ្សារដែក) បើសិនជាគាត់នៅរហូតមកដល់ឥលូវក៏វាអាចមានប្រព័ន្ធទំនាក់ទំនងអីដែលអាចស្រាវជ្រាវរកគ្នាឃើញស៊ើបពីប្រវត្តិគ្នាឃើញ (សំលេងផ្សារដែក) តែឥលូវវាស្ងាត់ឈឹងរហូតទាល់តែសព្វថ្ងៃនឹងចឹងណាស់ ចឹងក្រុមមគ្រួសារដាក់ចិត្តថាប្រហែលជា ៨០% ពួកគាត់អាចស្លាប់ (សំលេងផ្សារដែក)!

ក៖ ចាស!

ខ៖ ព្រោះអត់មានដំណឹងសោះ!

ក៖ ចាស ចុះកាលនឹងលោកពូគេជំលៀសលោកពូទៅណាដែរ?

គ៖ អត់មានភ្លើងផងបង (សំលេងអ្នកដទៃ)!

ខ៖ អត់ផងកាលនឹងកើតនៅភ្នំពេញជំនាន់ពលពតពូទើបអាយុបានពីរខួបនឹងពីរខួបបីខួបនឹងហើយគេអត់ជំលៀសទៅណាទេគេគ្រាន់តែជំលៀសទៅជាយៗភ្នំពេញយើងទេ (សំលេងផ្សារដែក) កាលនឹងកើតនៅទួលគោកយើងនឹងរោងចក្របីគ្រីតតុងយើងនេះដល់ពេលជំនាន់អាពតឆ្នាំ៧៦ (១៩៧៦) គេជំលៀសអោយមកនៅស្ទឹងមានជ័យនឹងម៉ងកន្លែងរោងចក្រមួយនៅស្ទឹងមានជ័យនឹងកន្លែងភូមិឬស្សីនឹងយើងនៅនឹងរហូតនឹងតែគ្រាន់តែថាដូរផ្ទះពីរមួយកន្លែងទៅមួយកន្លែនៅជិតៗគ្នានឹងឯង (សំលេងផ្សារដែក) នឹងរហូតប៉ុន្មានជាងដប់ឆ្នាំនឹងគឺផ្ទះពីរបីកន្លែងនឹងដូរនៅជិតៗគ្នានឹង ឯងអត់ទៅណាឆ្ងាយទេនៅម្តុំនឹង!

ក៖(សើច) ចឹងមានន័យថាលោកពូនៅតូចពេកកាលនឹងលោកពូអត់ដឹង....

ខ៖ នៅតូចយើងអត់ដឹង.....

ក៖ អត់មានៗការចងចាំអីទេព្រោះអីកាលនឹងលោកពូទើបតែបានបីខួប?

ខ៖ នឹងហើយ!

កៈ ចាស!

ខៈ ឆ្នាំ ៧៩-៨០ (១៩៧០-១៩៨០) យើងបែកអឺ.....៧៩-៨០ នឹងយើងជិតបែកពីអាពតហើយណាស់ដល់ពេលជិតបែកអាពត អេ....កាលនឹងមិនមែនបីខួបទេដូចទើបតែពីរខួបរបៀបដូចថាទើបតែចេះដើរនឹងណាស់ នឹងហើយដល់ពេលបែកអាពត ៧៩-៨០ នឹងម៉ោបានចេញមកនៅនឹងស្ទឹងមានជ័យនឹងរហូតមក!

កៈ ចឹងលោកពូមានធ្លាប់លឺឪពុកម្តាយនិយាយអ្វីទេទាក់ទងជាមួយនឹងសម័យពលពតនឹង?

ខៈ (សំលេងម៉ូតូឡាន) អឺ ....តាមពិតវាមានច្រើនតែគ្រាន់តែថាការលំបាកនឹងប្រជាជនទូទៅជួបដូចតែគ្នាណាស់ជួបដូចគ្នា!

កៈ ចាស!

ខៈ ជួបដូចគ្នាអ្នកពីមុនមកក៏គាត់ធ្លាប់ដឹងធ្លាប់ប្រើជីវិតឆ្លងកាត់កាលជំនាន់អាពតនឹងវាមានៗអត់ខុសគ្នាទេគ្រាន់តែថានៅកន្លែងខ្លះវារៀងធូរបន្តិចកន្លែងខ្លះគេរៀងរិតបន្តឹតយើងនឹងក៏រៀងពិបាកខ្លាំងតែប៉ុន្នឹងទេនឹងបើតាមការស្តាប់ចាសៗដែលគាត់និយាយមកណាស់!

កៈ ចាស!

ខៈ តែបើពីថាសិទ្ធិសេរីភាពអីៗនឹងគ្មានទេដូចតែគ្នា(សំលេងផ្សារដែក) គ្មានពីណាអាចមានសិទ្ធិជាងពីណាទេក្រៅពីខាងមេកងមេអីនឹង អានឹងបើតាមលឺចាសៗគាត់និយាយណាស់ហើយពូអត់ច្បាស់ទេ!

កៈ ចាស ហើយអឺ....លោកពូមានបានសួរពួកគាត់ដែរឬទេកាលសម័យពលពតថាគាត់ត្រូវបានគេជំលៀសទៅណាទាំងក្រុមគ្រួសារឬក៏បែកគ្នា ឬក៏គាត់ត្រូវជួបនឹងការលំបាកអីគេខ្លះកាលសម័យនឹងតើគាត់ធ្លាប់ប្រាប់លោកពូដែរឬទេ?

ខៈ ធ្លាប់ដឹងប៉ុន្តែគេអត់ជំលៀសយើងទៅណាឆ្ងាយទេ គ្រួសារយើងរបៀបថាជាប្រធានសហគមន៍គេហៅថាសហករណ៍ណាស់ជំនាន់នឹងបើតាមដឹង

គេហៅថាសហករណ៍នៅជុំគ្នាទេពីព្រោះថាប៉ាគាត់ជាមេជាងចឹងគេត្រូវការអ្នកបច្ចេកទេសស ម័យនឹងគាត់ជាជាងចឹងគេទុកអោយគាត់ធ្វើជាមេជាងប្រចាំនៅរោងចក្រៗភូយយើងនៅនឹងស្ទឹងមានជ័យនេះព្រោះរោងចក្រនឹងរោងចក្រតំប្បាញចឹងគេត្រូវការជាងដើម្បីធ្វើគ្រឿងចក្រធ្វើគ្រឿងកី
គ្រឿងតំប្បាញអីនឹងចឹងគ្រួសារយើងក៏វាមិនសូវជាមានការគាបសង្កត់ប៉ុន្មានដែរព្រោះយើងមានចំណេះដឹងខាងផ្នែកបច្ចេកទេចចឹងគេមិនសូវធ្វើបាបទេតែបើសិនជានិស្សិត
ឬក៏បញ្ញាវ័ន្តមន្ត្រីរាជការ
កំលាំងប្រដាប់អាវុធអីផ្សេងៗអានឹងប្រហែលជា....នេះបើតាមពូបានលឺទេណាស់អានឹងប្រហែលជាគេគាបខ្លាំងណាស់ (គេធ្វើបាបខ្លាំងណាស់) អត់មានសិទ្ធិសេរីភាពទេហើយអោយតែគេដឹងនឹងក៏មិនសូវបានរស់យូរដែរ!

ក៖ ចាសៗលោកពូ ហើយបន្ទាប់ពីដាច់អាពតមកគាត់អត់មានបានផ្លាស់ទីលំនៅៗឯណាទេគឺគាត់នៅភ្នំពេញនឹងម៉ង?

ខ៖
(សំលេងផ្សារដែក)នៅភ្នំពេញនឹងរហូតក្រវិលៗគ្រាន់តែដូរពីរមួយកន្លែងទៅមួយកន្លែងជិតៗគ្នានឹងដូរតែសង្កាត់អីតិចតួចចឹងណាស់!

ក៖ ចាសៗ ហើយបន្ទាប់មកទៀតតើជីវិតរបស់លោកពូអឺ.....ពេលដែលមានការងារធ្វើហើយរហូតមកដល់ឥលូវនឹងណាស់
លោកពូមានអឺ.....មានការចេងចាំអីគេដែលលោកពូគិតថាវាពិបាកសំរាប់ជីវិតរបស់លោកពូ ហើយដែលធ្វើអោយលោកពូចងចាំហើយភ្លេចមិនបានសោះណាស់លោកពូ?

ខ៖ អូ....និយាយទៅជីវិតដូចក្មេងកំព្រាដែរព្រោះដើរចេញចិញ្ចឹមខ្លួនឯងតាំងពីអាយុ ១៦,១៧ ឆ្នាំមកម្លេះយើងមិនសូវបាននៅផ្ទះយើងមិនសូវបានននៅផ្ទះជិតដល់តាំងពីរៀនបាកឌុបមកពូចេញពីផ្ទះទៅនៅជាមួយឪពុកធំហើយឪពុកធំគាត់នៅខាងព្រែកលាភឯណោះកាលនឹងទៅរៀនខាងអឺ....នៅសាលាភូមិន្ទសិល្បះណាស់ហើយពូខ្ញុំគាត់លក់អឺ.....បើកហាងលក់បាយលក់ម្ហូបលក្ខណជាអាហារដ្ឋានចឹងណាស់នៅឯខាងជ្រោយចង្វានៅខាងព្រែកលាភចឹងក៏ស្នាក់នៅជាមួយគាត់ហើយមករៀននៅស្តាតចាស់នៅ

ឯសាលាភូមិន្ទណោះចឹងល្ងាច....ព្រឹកចេញជិះកង់មករៀនចឹងទៅល្ងាចទៅវិញនៅជាមួយគ្នាវិញហើយជួយរកស៊ីលក់ដូរជួយគាត់វិញខ្លះហើយ (សំលេងកូនក្មេង)
ចាប់ពីនឹងមកយើងមិនសូវបាននៅ...ពូមិនសូវបាននៅផ្ទះទេព្រោះរសាត់អណ្តែតរហូតដើរធ្វើការតាមខេត្តធម្មតាអង្គការគេសូវនៅ (សំលេងកូនក្មេង)
ឈររំពឹងតែមួយកន្លែងទេគោលដៅដូចពូប្រាប់ពីដើមមិញនឹងគឺគេធ្វើតាមតំបន់ព្រំដែនជាយដែនឆ្ងាយៗដែលប្រព័ន្ធព័តមានទៅមិនដល់ចឹងៗយើងកម្រនឹងមានឪកាសបានចូលផ្ទះណាស់វាមួយខែអីចូលផ្ទះបានពីរថ្ងៃបីថ្ងៃអីអស់ហើយយ៉ាងយូរជួនកាលពីរខែអីមិនទាន់បានចូលផ្ទះម្តងផងដល់ថ្នាក់ម្តាយចង់ភ្លេចមុខក៏មានដែរពេលខ្លះ (សើច)
ចុះបើកាលជំនាន់នោះមិនទាន់មានទូរស័ព្ទអាចមើលមុខគ្នាឃើញដូចជំនាន់នេះឯណា!

ក៖ ចាស!

ខ៖ ដល់ឥលូវនេះចង់តេមើលមុខគ្នានឹកកូននឹកសង្សានឹកប្តីនឹកប្រពន្ធអីតេមើលមុខគ្នាបាន!

ក៖ (សើច) ចាសត្រូវហើយ ចឹងលោកពូនឹកផ្ទះណាស់កាលនឹង?

ខ៖ នឹកតែអត់ដឹងធ្វើម៉េច!

ក៖ (សំលេងមនុស្សនិយាយគ្នា) ចុះកាលនឹងការលំបាករបស់លោកពូមានអីខ្លះដែរលោកពូ?

ខ៖
អឺ....ធម្មតាយើងដើរធ្វើការស្រុកគេហើយទំនៀមទំលាប់នៃការរស់នៅៗតាមតំបន់នីមួយៗគឺវាខុសៗគ្នាទាំងអស់ទៅតាមតំបន់ទាំងការនិយាយទាំងការហូបចុកហើយនឹងទាំងការរស់នៅវាមានការខុសគ្នាពីមួយតំបន់ទៅមួយតំបន់ពីមួយខេត្តទៅមួយខេត្តយើងទំរាំនឹងយើងទៅផ្សាំខ្លួនទៅនឹងមួយតំបន់មួយនឹងយើងត្រូវចំណាយពេលពីកន្លះខែទៅមួយបានយើងអាចចូលចុះធ្វើការជាមួយអ្នកភូមិនឹងកើតអានឹងហើយជាការលំបាកជំហ៊ានដំបូងហើយ(សំលេងរថយន្ត)
ជំនាន់នឹងកង្វះខាតភាពចេះដឹងការចេះដឹងរបស់ប្រជាជនយើងរបស់ពលរដ្ឋយើងវានៅមានកំរិតចឹងអ្វីដែលយើងយកទៅវាសំរាប់គាត់ធ្វើអោយគាត់ពិបាកនឹងទទួលយកណាស់
(សំលេងកូនក្មេង)
យើងត្រូវរកវិធីសំរបសំរួលត្រូវរកវិធីសំរាប់ដោះស្រាយដើម្បីអោយយើងនិយាយទៅធ្វើម៉េចគាត់ស្តាប់យើងបានហើយពន្យល់គាត់ទៅអោយគាត់ងាយយល់រហូតដល់មាន(សំលេងឡាននិងម៉ូតូ)អាលើកឧទាហរណ៍ជាក់ស្តែង (សំលេកូនក្មេង)

ឬក៏លើកដូចជារឿងកំប្លែងខ្លីថ្មីអីយកមកសំដែងអោយគាត់មើលឬលើកយកមកនិយាយអោយគាត់ស្តាប់ចឹងបានគាត់ឆាប់យល់.....

គ៖ នេះមួយរយហ្អែស (សំលេងកូនក្មេង)!

ខ៖ បើយើងចុះនិយាយជាមួយគាត់ត្រង់ៗដូចយើងរៀននៅសាលាចឹងគាត់អត់ទេគាត់មិនងាយយល់ទេ អ្នកជនបទចំណោះដឹងគាត់នៅមានកំរិតចឹងគាត់ (សំលេងកូនក្មេង) ពិបាកនឹងទទួលយកទាំងអស់នឹងសុទ្ធតែជាបទពិសោធន៍នៃការលំបាកហើយ និយាយពីពិបាកៗមែនទែនម៉ងណាស់ត្រង់កន្លែងនឹងណាស់ (ពិបាកខ្លាំង)!

ក៖ ចាស!

ខ៖ (សំលេងកូនក្មេង) ពិបាកឡើងគោលដៅមួយភូមិនឹងយើងត្រូវធ្វើតែបីខែឆ្លាយទៅដល់បួនទៅប្រាំខែបានធ្វើហើយបានអាចពន្យល់អោយពួកគាត់អោយយល់អស់ (ក្រហែម) ហើយអស់នឹងក៏មិនអស់ ១០០% ដែរ ៧០% អីនឹងគឺខ្លាំងហើយដែរយើង....ដែរគាត់អាចទទួលយកបានណាស់ព្រោះនៅមានប្រជាជនយើងមួយចំនួនខ្លះគាត់នៅប្រកាន់គោលគំនិតចាស់របស់គាត់តាមដែលគេហៅថា(សំលេងមនុស្សនិយាយគ្នា)ទំនៀមទំលាប់របស់គាត់ៗអត់ទទួលយកអ្វីដែលថ្មីដែលយើងបានផ្តល់ទៅអោយគាត់ទេ(សំលេងរថយន្តនឹងសំលេងកូនក្មេង) ចឹងយើងមាន ២០% ទៅ ៣០ % ដែរយើងអាចធ្វើការជាមួយគាត់ណាស់អានឹងក៏វាបរាជ័យមួយដែរក៏ជាឧបសគ្គមួយដែរសំរាប់ការងារយើងណាស់វាធ្វើអោយការងាររបស់យើងមិនបានល្អ ១០០% (សំលេងធ្លាក់របស់) ទាំងនេះសុទ្ធតែជាបទពិសោធន៍ពិបាកៗហើយ (សើច)!

ក៖ ចាសលោកពូ!

ខ៖ (ក្រហែម)!

ក៖ ឃើញថាលោកពូតស៊ូនៅក្នុងជីវិតមែនទែន ហើយបន្ទាប់មកតើមានរឿងអីគេដែរធ្វើអោយលោកពូចងចាំហើយសប្បាយចិត្តជាងគេ?

ខ៖
អ៊ឹម....ដែលចងចាំហើយសប្បាយចិត្តមានតែប្រវត្តិផ្ទាល់ខ្លួនរឿងផ្ទាល់ខ្លួនអានឹងវារៀងពិបាកនិយាយបន្តិច (សំលេងផ្សារដែក) ដល់តែសប្បាយចិត្តមែនទែន (សំលេងរថយន្ត) គឺនៅពេលដែលចេះស្រលាញ់ចង់បានប្រពន្ធចង់បានកូនមានគ្រួសារទោះបីយើងមិនមានលុយស្តុកស្តមដូចគេគ្រាន់តែយើងមានជីវភាពរស់នៅសាមញ្ញៗសមរម្យដូចគ្នាប៉ុន្តែយើងអាចរស់នៅបានដោយស្រួលយើងមិនលំបាកលំបិនយើងមិនលំបាកអឺ....ដូចអ្នកខ្លះគាត់មួយកញ្ច្រែងមួយកញ្ច្រៀមួយល្អីដើរលក់ត្រង់នេះមួយចុបត្រង់នោះមួយចុប (មិននៅមួយកន្លែង) គ្រាន់តែរស់បានតែមួយពេលៗ (រកបានតែមួយក្រពះ) ចឹងណាស់យើងវាមិនដល់ថ្នាក់នឹង!

ក៖ ចាស!

ខ៖ គ្រាន់តែថាយើងអាចរស់នៅមានរបស់ប្រើប្រាស់សមរម្យដូចគេដូចឯងនៅក្នុងសង្គម (សំលេងម៉ូតូ)
មិនជាខ្ពង់ខ្ពស់ដូចគេមួយចំនួនដែលគេធូរធារមានមុខមានមាត់មានអឺ....មុខរបរអីធំដុំនោះទេក៏ប៉ុន្តែគ្រាន់តែយើងអាចនៅជាធនកណ្តាលជាមួយនឹងមនុស្សសាមញ្ញទូទៅដែលយើងអាចរស់បាន!

ក៖ ចាស!

ខ៖ មិនអីទេ!

ក៖ ចាសលោកពូ
ហើយអឺ....តាំងពីក្មេងមកដល់ឥលូវនឹងលោកពូមានក្តីស្រម៉ៃចង់ធ្វើអីមួយទេកាលនៅពីក្មេង?

ខ៖ ពី...ក្តីស្រម៉ៃសំរេចបានពីរហើយ (ក្រហែមនិងសំលេងម៉ូតូ)
បើកាលពីតូចស្រលាញ់ខាងផ្នែកសិល្បះណាស់ស្រលាញ់ណាស់ផ្នែកសិល្បះ
(សំលេងមនុស្សនិយាយគ្នា)
ហើយកាលជំនាន់នឹងមិនទាន់ចំរៀងអីមានណាទូរទស្សន៏អីទូរស័ព្ទអីផ្សព្វផ្សាយទេ
ដូចឥលូវមាន Page មានស្អីៗដែលយើងមើលបាន You tube យូរអីដែលយើងអាចមើលបានចំរៀងអីៗនឹងអត់មានទេមានតែកូនម៉ាញ៉េចាក់កាសែតតូចមួយនឹងក៏យើងវាចាក់ស្តាប់ចំរៀងរាល់ថ្ងៃនឹងទៅម៉ោៗចឹងទៅកាលនឹងស្រលាញ់ចំរៀងដល់ពេលធំឡើងបានធ្វើការខាងផ្នែកសិល្បះរយះពេលប្រាំមួយទៅប្រាំពីរឆ្នាំដែរអានឹងសំរេចក្តីស្រម៉ៃទីមួយ

ដែលកាលពីតូចចង់ក្លាយជាអ្នកសិល្បះមួយហើយ ក្តីស្រម៉ៃទីពីរ (ក្រហែមនឹងមានសំលេងមនុស្សនិយាយគ្នា) ការងារសំណង់នឹងឯង (សំលេងស៊ីផ្លេឡាន) គិតថាពីមុនមកធ្វើជាកម្មករគេធ្វើកូនជាងគេពិបាកណាស់ (សំលេងម៉ូតូ) ដល់ថ្ងៃក្រោយទៅធ្វើមេគេអោយបានម៉ងណាស់ប៉ុន្តែឥលូវនឹងវាទើបតែនឹងបាន ៥០% យើងនៅមិនទាន់បានសំរេច ១០០% ទេ (សំលេងម៉ូតូ) យើងត្រូវធ្វើជាមេគេអោយបានត្រូវចេះគ្រប់គ្រងមនុស្សត្រូវចេះធ្វើការងារត្រូវចេះបញ្ចូរការងារ ប៉ុន្តែអ្វីដែលយើងថាមិនទាន់បានសំរេច ១០០% ដោយសារយើងគ្រាន់តែបានគ្រប់គ្រងផ្នែកខាងបច្ចេកទេសចំណែកខាងបញ្ហាសេដ្ឋកិច្ចខាងផ្នែកហិរញ្ញវត្ថុដែលយើងចង់គ្រប់គ្រងទាំងដុល (គ្រប់គ្រងទាំងអស់) ដូចជាក្រុមហ៊ុនក្រុមអីនឹងយើងមិនទាន់មានលទ្ធភាពធ្វើទៅរួច (សំលេងឡាន) ចឹងអានឹងនៅ ៥០% ទៀតយើងកំពុងតែស្រវាយកមកកំពុងតែព្យាយាមសំរេចវាណាស់ (សំលេងរថយន្ត) នឹងយើងនៅខ្វះអានឹងមួយទៀត!

ក៖ ចាស ចឹងលោកពូនៅខ្វះតែមួយនឹងទៀតគ្រប់ហើយន៍លោកពូ?

ខ៖ នឹងហើយគ្រប់ហើយគោលដៅធំចំបងដែលចង់បានគឺពីរនឹងសិល្បះនឹងសំណង់ស្រលាញ់ខាងសំណង់នឹងព្រោះម្យ៉ាងទៀតវាជាមុខរបរបន្សល់ទុកពីដូនតាបន្សល់ពីជីតាដល់ឪពុកបន្សល់ពីឪពុកដល់កូនតែជំនាន់ក្រោយអត់អោយកូនធ្វើខាងផ្នែកសំណង់ទេ (សើច)!

ក៖ (សើច) ម៉េចចឹងលោកពូ?

ខ៖ ខ្ញុំចង់អោយគេធ្វើការងារអីដែលស្រួលជាងនឹងធ្វើការងាប្រើខួរក្បាលបន្តិចមែនប៉ុន្តែកុំអោយវាហាត់កំលាំងធ្វើការសំណង់ហាត់ទាំងកំលាំងហាត់ទាំងខួរក្បាលហើយទាមទារបច្ចេកទេសនឹងចំណេះដឹងច្រើនពាក់ព័ន្ធនឹងផ្នែកសំណង់នឹងព្រោះថាយើងចេះល្មមៗក៏យើងអត់ហ៊ានទទួលធ្វើបានដែរពីព្រោះការងារនេះសុទ្ធតែជាការងារប្រឈមនឹងគ្រោះថ្នាក់!

ក៖ ចាសលោកពូ!

ខ៖ គ្រោះថ្នាក់ផង (សំលេងមនុស្សនិយាយគ្នា) ហើយបើសិនជាយើងធ្វើខូចខាតទៅមានឧប្បទ្វេរហេតុឬយថាហេតុណាមួយកើតឡើងប៉ះពា

ល់ដល់អាគារប៉ះពាល់ដល់សំណង់របស់គេអានឹងគឺវាសុទ្ធតែជាការងារទទួលខុសត្រូវសងគេពេញថ្លៃហើយអានឹងណាស់ចឹងសុទ្ធតែការងារប្រថុយហើយការងារ (សំលេងឡាន) សំណង់នឹងការងារសំណង់ជាការងារប្រថុយបើសិន(សំលេងមនុស្សនិយាយគ្នា) ជាយើងមិនអាចទទួលគឺអត់ទទួលម៉ងកន្លែងណាដែលយើងគិតថាយើងអាចធ្វើបានលទ្ធភាពយើងអាចទៅបានអានឹងបានយើងធ្វើថ (សំលេងមនុស្សនិយាយគ្នា) ចឹងយើងនៅខ្វះខាតចំនុចនឹងមួយចំនុចដែរយើងអត់ទាន់បានសំរេចការគ្រប់គ្រងនឹងបាន ១០០%!

កៈ ចាស ចុះលោកពូគិតថាការងារនឹងបានផ្តល់ប្រាក់ចំណូលអោយលោកពូបានប្រហែលជាប៉ុន្មានភាគរយដែរសំរាប់ចិញ្ចឹមគ្រួសារណាស់?

ខៈ ហ៊ឹម! យើងពិបាកគិតជាភាគរយណាស់ប៉ុន្តែជាមធ្យមវាទៅតាមសំណង់ធំសំណង់តូចណាស់សំណង់ធំសំណង់តូចបើសិនជាយើងធ្វើការងាររយះពេលលឿនហើយមុនការដែលយើងគ្រោងទុកហើយមុនការដែលយើងវាយតំលៃដែលយើងព្រៀងទុកចឹងណាស់(រួចរាល់មុនអ្វីដែលរំពឹងទុក) យើងអាចសល់បានច្រើនចំណូលអាចបានពីបួនទៅប្រាំរយអីចឹងណាស់ហើយបើវាមានការយឺតយ៉ាវខាងផ្នែកបច្ចេកទេសឬក៏ផ្នែកណាមួយអានឹងចំណូលក៏វាធ្លាក់ចុះទៅតាមនឹងដែរឧបមាថាផ្ទះមួយគោលដៅយើងធ្វើកន្លះឆ្នាំយើងធ្វើអោយហើយ ប៉ុន្តែយើងធ្វើអត់ហើយទេក្នុងកន្លះឆ្នាំនឹងវាលោតទៅដល់ប្រាំពីរខែឬក៏ប្រាំបីខែចឹងចំណូលដែលយើងត្រូវសល់វាត្រូវធ្លាក់វាត្រូវថយទៅតាមនឹងណាស់ហើយបើយើងកំណត់ថាយើងត្រូវធ្វើត្រឹមប្រាំមួយខែអោយហើយ (ប្រាំមួយខែអោយរួចរាល់) ប៉ុន្តែតែបួនខែទេយើងធ្វើហើយចំណូលរបស់យើងត្រូវកើនឡើងសល់លុយបើក្នុងមួយខែយើងត្រូវចំណាយលុយពី ៤០០$ ទៅ ៥០០$ អោយថ្ងៃពលកម្មថ្ងៃជាងចឹងតែកាលណាឈ្នួលពីរម៉ឺនសំរាប់ប្រាំខែឬក៏ប្រាំមួយខែបើយើងដកបីពាន់ក្នុងមួយខែយើងគិតថាបីពាន់ក្នុងមួយខែ(សំលេងម៉ូតូ) ចុះបើយើងធ្វើតែបួនខែយើងអស់តែ ១២០០០$ ទេចឹងឈ្នួល ២០០០០$ យើងមិនត្រូវនៅសល់ ៨០០០$ ប្រាំបីពាន់យើងយកទៅលើការចំណាយការហូបចុកសាំងម៉ូតូកាតទូរស័ព្ទអីៗផ្សេងៗការស្លៀកពាក់របស់យើងមួយចប់ចឹងវា...យើងអាចមានចំណូលបីទៅបួនពាន់ក្នុងរយះពេលប្រាំមួយខែនឹងតែបើៗបីទៅបួនពាន់ក្នុងរយះប្រាំទៅប្រាំមួយខែ

នឹងយើងយកមកចែកនឹងខែមកយើងបានប្រាំទៅប្រាំមួយរយអីដែរក្នុងមួយខែ(ស៊ីផ្លេឡាន) ប៉ុន្តែបើគិតក្នុងល័ក្ខខណ្ឌថាវាលើសពី៦ខែនឹងទៅចឹងអាប្រាំមួយរយនឹងវាត្រូវថយមកតាមនឹងវិញណាស់វាធ្លាក់ពីប្រាំរយមកនៅបួនរយឬក៏ធ្លាក់ពីប្រាំរយមកនៅបីរយអានឹងទៅលើពេលវាលាដែរការងារសំណង់គឺវាផ្តោតសំខាន់ទៅលើចំនុចនឹងមួយដែលធ្វើអោយចំណូលយើងធ្លាក់ចុះឬក៏កើនឡើងដោយសារតែចំនុចមួយនឹង!

ក៖ ចំនុចពេលវេលានឹង....នឹងបច្ចេកទេស!

ខ៖ នឹងហើយនិងបច្ចេកទេសនិងពេលវេលានឹងឯង!

ក៖ ចាសលោកពូ! អ៊ឹម...ចឹងខ្ញុំឃើញថាបំណងប្រាថ្នារបស់លោកពូសង្ឃឹមថាវានឹងបានសំរេចណាស់លោកពូហើយជូនពរលោកពូសំរាប់បំណងប្រាថ្នាហើយនឹងទាក់ទងជាមួយនឹងទៅថ្ងៃអនាគតផ្សេងៗដែលមើលអត់ឃើញតែសុំអោយបំណងប្រាថ្នារបស់លោកពូបានសំរេចនៅក្នុងឆ្នាំនឹង(សើច)!

ខ៖ នឹងហើយ!

ក៖ (សើច) ចាសហើយអឺ....ជាចុងក្រោយលោកពូមានពាក្យពេជន៍អីដើម្បីផ្តែផ្តាំដល់អ្នកដែលគាត់បានចូលទៅស្តាប់សំលេងរបស់លោកពូផ្ទាល់អ្នកដែលគាត់ចូលទៅក្នុងវេបសាយហើយវាយឈ្មោះរបស់លោកពូទៅគាត់អាចនឹងមើលហើយនឹងស្តាបនូវសំលេងរបស់លោកពូជាពិសេសកូនចៅលោកពូជំនាន់ក្រោយទៀតដែលចង់ថាអ៍....នេះគឺជាសំលេងរបស់ឪពុកខ្ញុំអឺ....ជីតាខ្ញុំអីចឹងណាស់ចឹងលោកពូអាចមានពាក្យពេជន៍អីដើម្បីនឹងផ្តែផ្តាំទៅពួកគាត់ដែរទេ?

ខ៖ គ្រាន់តែថាធម្មតាពីមួយជំនាន់ទៅមួយជំនាន់បទពិសោធន៍វាខុសគ្នាចឹងណាស់តែគ្រាន់តែថាបទពិសោធន៍ដែលមានកន្លងមកយើងធ្វើចងក្រងទុកជាមេរៀនសំរាប់អ្នកជំនាន់ក្រោយ
គាត់យកបទពិសោធន៍កន្លែងនឹងឬយកមេរៀនជីវិតទាំងអស់ទៅដើម្បីអប់រំខ្លួនគាត់កន្លែងណាដែលគាត់គិតថាមិនទទួលយកបាន (សំលេងមនុស្សស្រី)
ដូចថាកន្លែងនឹងវាមិនល្អអីចឹងការងារធ្វើទៅដែលវាមិនកើតវាមិនរួចគាត់មិនអាចធ្វើបានអានឹងគាត់យកវាទុកគ្រាន់តែជាមេរៀន(សំលេងរញ៉េរញ៉ៃរំខាន)
ហើយបើបទពិសោធន៍ល្អៗដែលយើងធ្វើបានដែលយើងសំរេចបានអានឹងបានគាតក៏ៗយកជា

មេរៀនមួយដែរដើម្បីអី
ដើម្បីគោលដៅជីវិតរបស់គាត់ដែលមានគោលដៅជីវិតដូចគ្នាឧបមារថាពូគោលដៅពូខាងសំណង់ចឹងៗបើពូសំរេចការងារខាងសំណង់ចឹងអ្នកក្រោយៗទៀតដែរមានចំណូលចិត្តខាងសំណង់ចឹងគាត់អាចយកអានឹងធ្វើជាបទពិសោធន៍ជីវិតសំរាប់គាត់ដើម្បីសំរេចគោលដៅជីវិតរបស់គាត់បានដូចគ្នា(សំលេងកូនក្មេង)ចឹងណាស់!

ក៖ ចាស!

ខ៖ តែប៉ុណ្ណឹងទេ!

ក៖ ចាស (សំលេងរញ៉េរញ៉ៃ)!

ខ៖ អានឹងគេហៅថាការចែករំលែងបទពិសោធន៍អោយគ្នាទៅវិញទៅមក!

ក៖ ចាសអរគុណច្រើនលោកពូ!

ខ៖ បាទ!